**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

# ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសមនិងជម្រាបលា

នៅព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ**លោកជំទាវ** Felicidade de Sousa Guterres ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ចូលជួបសម្តែងការគួរសមនិងជម្រាបលា ក្នុងឱកាសដែលលោកជំទាវបានបញ្ចប់បេសកកម្មការទូត នៅព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះ**លោកជំទាវ ឯកអគ្គរដ្ឋទូត** ដែលបានបញ្ចប់បេសកកម្មការទូតប្រកបដោយជោគជ័យ និងបានថ្លែងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់លោកជំទាវក្នុងការរួមចំណែកយ៉ាងសំខាន់ធ្វើឱ្យទំនាក់ទំនង និងកិច្ចសហប្រតិត្តិការរវាងកម្ពុជានិងទីម័រឡេស្តេ កាន់តែរីកចម្រើន និងទូលំទូលាយបន្ថែមទៀត តាមរយៈការផ្លាស់ប្តូរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរកន្លងមក និងការគាំទ្រគ្នាទៅវិញទៅមកនៅលើឆាកអន្តរជាតិ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានបញ្ជាក់ពីការត្រៀមផ្តល់កិច្ចសហការយ៉ាងពេញលេញរបស់កម្ពុជា ជាមួយឯកអគ្គរដ្ឋទូតថ្មីរបស់ទីម័រឡេស្តេ ដែលនឹងមកបំពេញបេសកកម្មការទូតនៅកម្ពុជា នាពេលខាងមុខ។

ជាការឆ្លើយតប **លោកជំទាវ ឯកអគ្គរដ្ឋទូត** បានសំដែងក្តីរីករាយ និងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ពិសេសក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលបានផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អធ្វើឲ្យការបំពេញបេសកកម្មការទូត របស់លោកជំទាវនៅកម្ពុជា ទទួលបានជោគជ័យ។ **លោកជំទាវ** បានកត់សម្គាល់ឃើញថា វិស័យទេសចរណ៍ និងកសិកម្ម គឺជាវិស័យលេចធ្លោសម្រាប់ពង្រីកកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរ ហើយលោកជំទាវបានសម្តែងនូវការចាប់អារម្មណ៍លើម្រេចកំពត ដែលមានគុណភាពខ្ពស់។ ឆ្លៀតក្នុងឱកាសនោះផងដែរ **លោកជំទាវ** បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជាចំពោះការផ្តល់អាហារូបករណ៍ជូននិស្សិតទីម័រឡេស្តេចំនួន១០ កន្លែង ហើយបច្ចុប្បន្នកំពុងសិក្សានៅប្រទេសកម្ពុជា។ **លោកជំទាវ** សង្ឃឹមថា នាពេលខាងមុខ នឹងមាននិស្សិតទីម័រឡេស្តេបន្ថែមទៀត មកសិក្សានៅកម្ពុជា។

ជាងនេះទៅទៀត **លោកជំទាវ ឯកអគ្គរដ្ឋទូត** បានកត់សម្គាល់ឃើញថា ប្រទេសកម្ពុជាមានបទពិសោធន៍ក្នុងដំណើរស្វែងរកសន្តិភាព រហូតដល់មានសន្តិភាព ស្ថេរភាពពិតប្រាកដ និងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចបានឆាប់រហ័ស។ ដូច្នេះ **លោកជំទាវ** បានចាត់ទុកកម្ពុជាអាចជាប្រទេសគំរូមួយសម្រាប់ទីម័រឡេស្តេ

និងប្រទេសដទៃទៀត រៀនសូត្រតាម។ ទន្ទឹមនេះ **លោកជំទាវ** ក៏បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានគាំទ្របេក្ខភាពរបស់ទីម័រឡេស្តេ ចូលជាសមាជិកអាស៊ាន នាពេលកន្លងមក។

នៅក្នុងជំនួបនោះផងដែរ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និង**លោកជំទាវ ឯកអគ្គរដ្ឋទូត** បានពិភាក្សាអំពីការជំរុញឲ្យមានកិច្ចសហប្រតិបត្តិការកាន់តែល្អ ជាពិសេសអនុវត្តឲ្យមានប្រសិទ្ធភាពនូវឯកសារមួយចំនួន ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស សេដ្ឋកិច្ច ការងារ និងកិច្ចព្រមព្រៀងរវាងសភាពាណិជ្ជកម្មនៃប្រទេសទាំងពីរ ដែលភាគីទាំងពីរបានចុះហត្ថលេខារួចហើយ ។បន្ថែមលើនេះ ភាគីទាំងពីរបានពិភាក្សាពន្លឿនការចុះហត្ថលេខាលើឯកសារកិច្ចសហប្រតិបត្តិការមួយចំនួន លើវិស័យទេសចរណ៍ ពាណិជ្ជកម្ម និងការអភិវឌ្ឍធនធានមនុស្ស។ ការអនុវត្ត និងការចុះហត្ថលេខាឯកសារខាងលើនេះ នឹងជំរុញកំណើនទេសចរ ទំហំពាណិជ្ជកម្ម និងវិនិយោគថែមទៀត។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ថា ប្រទេសកម្ពុជាមានបទពិសោធន៍ក្នុងការស្វែងរកសន្តិភាព បញ្ចប់សង្គ្រាម ហើយកសាងប្រទេសឲ្យមានសុខសន្តិភាពពេញលេញ និងរីកចម្រើនលើគ្រប់វិស័យ រហូតទទួលបានចំណាត់ថ្នាក់ជាប្រទេសមានកំណើនសេដ្ឋកិច្ចខ្ពស់នៅតំបន់យើងនេះ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានមានប្រសាសន៍បន្ថែមថា កម្ពុជារីករាយក្នុងការចែករំលែកបទពិសោធន៍ ក្នុងការដឹកនាំ និងអភិវឌ្ឍប្រទេសជាតិ។

នៅឱកាសនោះផងដែរ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និង**លោកជំទាវ ឯកអគ្គរដ្ឋទូត** បានពិភាក្សាផងដែរអំពីបញ្ហាតំបន់ និងអន្តរជាតិ ដែលជាកង្វល់រួមរបស់ប្រទេសទាំងពីរ៕